**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខៈ** ១១ សសរ

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ២០១១

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការការពារផលប្រយោជន៍ស្ត្រី នៃទីស្តីការគណៈរដ្ឋមន្ត្រី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
-យោងរបាយការណ៍នៃការប្រជុំគណៈកម្មាធិការការពារផលប្រយោជន៍ស្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១១
-យោងតាមការចាំបាច់ចំពោះមុខ

## សម្រេច

**ប្រការ១** : តែងតាំងគណៈកម្មាធិការការពារផលប្រយោជន៍ស្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១ | លោកជំទាវ | **ឆាយ** | **ម៉ាន់ឡឿន** | ប្រធាន |
| ២ | លោកជំទាវ | **មាសសាឯម** | **ដានី** | អនុប្រធាន |
| ៣ | លោកជំទាវ | **សុខ** | **វិឡាយ** | អនុប្រធាន |
| ៤ | លោកជំទាវ | **ទុខ** | **សុគន្ធ** | សមាជិក |
| ៥ | លោកជំទាវ | **ភុយ** | **ពិសី** | សមាជិក |
| ៦ | លោកជំទាវ | **ចំរើន** | **ភគិភា** | សមាជិក |
| ៧ | លោកស្រី | **ឆែម** | **ឆាង** | សមាជិក |
| ៨ | លោកស្រី | **ចិន** | **ច័ន្ទមុនី** | សមាជិក |
| ៩ | លោកស្រី | **ស្រី** | **ម៉ាលីន** | សមាជិក |
| ១០ | លោកស្រី | **ឆាយគីម** | **សុទ្ធី** | សមាជិក |
| ១១ | លោកស្រី | **លីម** | **សុគន្ធា** | សមាជិក |

| | | | | |
|---|---|---|---|---|
| ១២ | លោកស្រី | **ស៊ឹម** | **វ័ត្ថថា** | សមាជិក |
| ១៣ | លោកស្រី | **ឡាន់** | **ចរិយា** | សមាជិក |
| ១៤ | លោកស្រី | **កែវ** | **សុជាតិ** | សមាជិក |
| ១៥ | លោកស្រី | **មាស** | **សុផល** | សមាជិក |

**ប្រការ២** : តែងតាំងអនុគណៈកម្មការ ការងារឃោសនា និង អប់រំ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១ | លោកជំទាវ | **សុខ** | **ទិឡាយ** | ប្រធាន |
| ២ | លោកជំទាវ | **ចំរើន** | **កតិកា** | អនុប្រធាន |
| ៣ | លោកស្រី | **មូល** | **ច័ន្ទជាទី** | សមាជិក |
| ៤ | លោកស្រី | **ស្រី** | **ម៉ាលីន** | សមាជិក |
| ៥ | លោកស្រី | **ទុច** | **ធានី** | សមាជិក |

**ប្រការ៣** : តែងតាំងអនុគណៈកម្មការ ការងាររដ្ឋបាល និង ហិរញ្ញវត្ថុ ដែលមានសមាសភាព ដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១ | លោកស្រី | **ឆាយគីម** | **សុទ្ធី** | ប្រធាន |
| ២ | លោកស្រី | **លឹម** | **សុគន្ធា** | អនុប្រធាន |
| ៣ | លោកស្រី | **មាស** | **ឡា** | សមាជិក |
| ៤ | លោកស្រី | **ស៊ឹម** | **វ័ត្ថថា** | សមាជិក |
| ៥ | លោកស្រី | **ឡាន់** | **ចរិយា** | សមាជិក |

**ប្រការ៤** :គណៈកម្មាធិការនេះ មានភារកិច្ចជាសេនាធិការពាំនាំនូវគោលការណ៍របស់ថ្នាក់ដឹកនាំស្ថាប័នផ្សព្វផ្សាយ ជូនដល់នារី និង ទទួលសំណូមពរ បញ្ហាប្រឈមនានា ព្រមទាំងការពារផលប្រយោជន៍របស់មន្ត្រីរាជការនារី រួចលើកជាអនុសាសន៍ជូនដល់ថ្នាក់ដឹកនាំដើម្បីពិនិត្យដោះស្រាយនិងសម្រេច។

**ប្រការ៥** : អនុគណៈកម្មការ ការងារឃោសនា និង ផ្សព្វផ្សាយអប់រំមានភារកិច្ចរៀបចំផ្សព្វផ្សាយឯកសារស្តីពីគោលការណ៍បញ្ញាបយេនឌ័រ ពាក់ព័ន្ធនឹងវិស័យអប់រំ ច្បាប់ សុខភាព សីលធម៌សង្គម និង គ្រួសារ។

**ប្រការ៦** : អនុគណៈកម្មការ ការងាររដ្ឋបាល និង ហិរញ្ញវត្ថុមានភារកិច្ច ប្រមូលទិន្នន័យនារី រៀបចំកិច្ចប្រជុំលើកគំពោងថវិកា ប្រចាំឆ្នាំ ត្រីមាស និងធ្វើរបាយការណ៍ សំរាប់ជូនថ្នាក់ដឹកនាំពិនិត្យ និង សម្រេច។

**ប្រការ៧** :អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាព អាជ្ញាធរ ក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី និងសាម៉ីខ្លួន ដូចមានចែងក្នុងប្រការ១ ប្រការ២ ប្រការ៣ ខាងលើនេះ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

សុខ អាន

**ចម្លងជូនៈ**
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រី
- -ដូចប្រការ ៧ ដើម្បីអនុវត្ត
- -ឯកសារ កាលប្បវត្តិ